# Final Workshop on Formulation of a Waste Management Strategy for Phnom Penh 2018-2035

Meeting 09 January 2018









## សកម្មភាព ៤.៥ ពង្រឹងប្រព័ន្ធគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ

ដើម្បីលុបបំបាត់ការបោះចោលសំណល់វេជ្ជសាស្ត្រមិនត្រឹមត្រូវក្នុងចំណោមស្ថាប័ន/អង្គភាពអ្នកផ្តល់សេវាសុខាភិបាល និងលើកកម្ពស់ប្រសិទ្ធភាពយន្តការគ្រប់គ្រងបច្ចុប្បន្ន។

ក. *លើកកម្ពស់ការយល់ដឹង និងការបណ្តុះបណ្តាលអំពីការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រដល់អ្នកផ្តល់សេវាសុខភាព*

បុគ្គលិកសុខាភិបាលគួរមានការយល់ដឹងច្បាស់លាស់អំពីសំណល់វេជ្ជសាស្ត្រ ប្រភេទសំណល់ បច្ចេកទេសបោះចោលឲ្យបានត្រឹមត្រូវ ព្រមទាំងហានិភ័យពាក់ព័ន្ធនឹងការបោះចោលសំណល់វេជ្ជសាស្ត្រដែលមិនត្រឹមត្រូវ។ គួរមានបុគ្គលម្នាក់ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រង និងត្រួតពិនិត្យការអនុវត្តនៅតាមមណ្ឌលសុខភាពនីមួយៗ។ ត្រូវរៀបចំយុទ្ធនាការផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងសាធារណៈអំពីហានិភ័យនៃការប៉ះពាល់ជាមួយសំណល់វេជ្ជសាស្ត្រ។

ខ. *ការតាមដានឲ្យបានតឹងរឹងទៅលើការអនុវត្តរបស់មណ្ឌលវេជ្ជសាស្ត្រទាំងអស់ និងដាក់ពិន័យធ្ងន់ធ្ងរចំពោះអ្នកផ្តល់សេវាសុខាភិបាលដែលបោះចោល និងវេចខ្ចប់សំណល់មិនបានត្រឹមត្រូវ។*

ក្រសួងសុខាភិបាលគួរតាមដាន និងសង្កេតឲ្យបានញឹកញាប់ទៅលើការអនុវត្តការបោះចោលសំណល់វេជ្ជសាស្ត្រទាំងនៅទីតាំងសាធារណៈ និងឯកជន។ ក្រសួងគួរសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីស្វែងរកគ្លីនិកដែលគ្មានអាជ្ញាប័ណ្ណដើម្បីចាត់វិធានការជាបន្ទាន់។ គួរមានប្រព័ន្ធ ឬខ្សែទូរសព្ទបន្ទាន់ដែលសាធារណជនអាចរាយការណ៍អំពីករណីអនុវត្តខុសក្រមសីលធម៌របស់អ្នកផ្តល់សេវាសុខាភិបាល ជាពិសេសអំពីការបោះចោលសំណល់វេជ្ជសាស្ត្រ។

## សកម្មភាព ៤.៥ ពង្រឹងប្រព័ន្ធគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ (បន្ត)

គ. *បង្កើនប្រសិទ្ធភាពតាមរយៈការគ្រប់គ្រងភស្តុភាកាន់តែល្អប្រសើរ និងការរៀបចំផែនការប្រកបដោយប្រសិទ្ធភាព*

- ការចែកចាយទ្រង់ទ្រាយធំនូវធុងសំរាមដែលរចនាឡើងជាពិសេសសម្រាប់សំណល់វេជ្ជសាស្ត្រ
- ការពង្រីកឡដុតសំណល់វេជ្ជសាស្ត្របច្ចុប្បន្ន និងបរិក្ខារពាក់ព័ន្ធផ្សេងៗទៀតដើម្បីឆ្លើយតបនឹងការកើនឡើងនូវសំណល់វេជ្ជសាស្ត្រ។ ប្រសិនបើអាច ត្រូវកាត់បន្ថយចម្ងាយដឹកជញ្ជូនទៅកាន់ឡដុត។ ត្រូវធានាថា ការប្រើប្រាស់ឡដុតនឹងមិនប៉ះពាល់ដល់បរិស្ថាន ហើយត្រូវតាមដានដំណើរការឡឲ្យបានជាប្រចាំ។ ត្រូវបង្កើនចំនួនរថយន្តប្រមូលសំរាមដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រមូល។
- ត្រូវកំណត់ពេលប្រមូលសំរាមឲ្យបានច្បាស់លាស់៖ ការប៉ះពាល់ជាមួយសំណល់វេជ្ជសាស្ត្រអាចមានផលវិបាកធ្ងន់ធ្ងរភ្លាមៗលើសពីសំណល់ធម្មតា។ ដូច្នេះសំណល់វេជ្ជសាស្ត្រដែលបានប្រមូលគួរប្រមូលឲ្យបានឆាប់តាមដែលអាចធ្វើបានដើម្បីបញ្ចៀសហានិភ័យនៃការប៉ះពាល់ ជាពិសេសចំពោះអ្នកដើររើសសំរាម។ កាកបាទក្រហមកម្ពុជា គួររៀបចំកាលវិភាគប្រមូល ប្រកបដោយប្រសិទ្ធភាពដែលពាក់ព័ន្ធជាមួយតវិយាបថបោះចោលជាទូទៅនៅក្នុងតំបន់នីមួយៗនៃរាជធានីភ្នំពេញ។ កាលវិភាគគួរផ្សព្វផ្សាយទៅដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសមណ្ឌលសុខភាព។

# សូមអរគុណ!